# អំពី "នរក" ដែលខ្មែរជឿតាំងពីបុរាណកាល

ខ្មែរស្គាល់ពាក្យ "នរក" យូរអង្វែងមកហើយ តាមរយៈគម្ពីរ សិលាចារឹក និងចម្លាក់នានាថាជាស្ថានរបស់ពួកសត្វមានបាប រស់រងទុក្ខតាមកម្លាំងកម្មដែលសាងកាលពីអតីតជាតិ។ ពាក្យនេះលេចឡើងក្នុងសិលាចារឹកតាំងពីមុនសម័យអង្គរ ក្នុងន័យជាបណ្ដាសាអ្នកបំផ្លិចបំផ្លាញ "បុណ្យ" ឬ "ធម៌" (សមិទ្ធផល) ឱ្យធ្លាក់ទៅរងទុក្ខវេទនានៅស្ថាននរកដរាបព្រះចន្ទនិងព្រះអាទិត្យនៅតែមាន។ ចូលដល់សម័យអង្គរ គេឃើញចម្លាក់នៅជញ្ជាំងខាងត្បូងនៃប្រាសាទអង្គរវត្ត បង្ហាញពីសត្វនរកទាំងឡាយកំពុងរងទារុណកម្មផ្សេងៗ (រូបលេខ១) និងពពួកសត្វនរកថ្វាយបង្គំព្រះលោកេស្វរ ឆ្លាក់នៅប្រាសាទតានៃជាដើម (រូបលេខ២)។ លុះដល់ខ្មែរគោរពប្រតិបត្តិយកព្រះពុទ្ធសាសនាជាធំ ជំនឿអំពីនរកនៅតែឃើញបង្ហាញតាមរយៈគម្ពីរ កិច្ចពិធី និងជាពិសេសក្នុងគំនូរតាមវត្ត។



រូបលេខ១ ការធ្វើទារុណកម្មសត្វនរកនៅលើចម្លាក់ជញ្ជាំងខាងត្បូងប្រាសាទអង្គរវត្ត



រូបលេខ២ ចម្លាក់សត្វនរកថ្វាយបង្គំព្រះលោកេស្វរ ឆ្លាក់នៅហោជាងប្រាសាទតានៃ (សៀមរាប)

តាមព្រះពុទ្ធសាសនា បុថុជ្ជនពុំអាចឃើញនរកបានឡើយ មានតែព្រះអរិយបុគ្គលមានឥទ្ធិឫទ្ធិដូចជាព្រះពុទ្ធ ព្រះមោគ្គល្លាន ព្រះមាល័យ ឬព្រះបាទនេមិរាជ... ទើបឃើញបាន (រូបលេខ៣)។[1] ប្រការត្រង់នេះបើលើកយក "ព្រះមាល័យសូត្រ" មកនិទានគេដឹងថាស្ថាននរកមានរណ្ដៅធំៗចំនួន៨ ហើយមានស្ដេចយមរាជចំនួន៣២ និងនាយនិរយបាល

---

[1] ឱម ណាត្រី (ឆ្នាំ?): អារម្មកថា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឬយមបាលចំនួន១២៨ នៅបម្រើចាំកត់ត្រាទោស និងអានទោសថ្វាយស្ដេចយមរាជ (រូបលេខ៤-៥)។[2] រីឯក្រុមយមបាលនេះសោត គេហៅម្យ៉ាងទៀតថា "កិង្ករ"[3] មានមុខមាត់គួរឱ្យខ្លាច ហើយមានអាកប្បកិរិយាកាចសាហាវ វាយដំ និងធ្វើទារុណកម្មគ្រប់បែបយ៉ាងដល់អ្នកដែលធ្លាក់ក្នុងនរកនានា។ មិនតែប៉ុណ្ណោះ ក្រុមយមបាលមានឆ្កែចាំយាមផ្លូវនរកស្វែងរកសត្វនរក និងនាំសារផង។ ហេតុដូច្នេះ ទើបក្នុងពាក្យសូត្រពេលចាប់ពូតបាយបិណ្ឌថា "ខ្ញុំសូមចាប់បាយបិណ្ឌ មធុបាយាស ព្រះពុទ្ធបានត្រាស់ ពោធិសត្វផង ផ្ដាំទៅតាកឹង ឱ្យចាប់ឆ្កែចង សុំផ្លូវទៅផង យកបាយទៅជូនដូនតា"។[4]




រូបលេខ៣ ព្រះមោគ្គល្លាននិមន្តទតឋាននរក (គំនូរលើជញ្ជាំងខាងក្រៅព្រះវិហារវត្តអង្គរខាងត្បូង)





រូបលេខ៤-៥ យមរាជកាត់ក្ដីអ្នកស្លាប់ (គំនូរទសវត្សទី៥០ នៅវត្តភ្នំធនមន្ត និងវត្តចុងដាច)

---

[2] គង់ ឈួយ ១៩៦៤: ១៤-១៥

[3] សព្វថ្ងៃខ្មែរនៅស្គាល់ពាក្យ "កិង្ករ" ក្នុងពាក្យសូត្រពេលចាប់បាយបិណ្ឌ ដោយហៅក្លាយថា "តាកឹង"

[4] អាំង ជូលាន និង ស៊ីយ៉ុន សុភារិទ្ធ ២០១៥: ៦៨-៧១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើមើលក្នុងគំនូរតាមវត្តនានាសព្វថ្ងៃ យើងឃើញថាគេគូរបង្ហាញចូលគ្នាទាំងនរក និងប្រេត។ គំនូរទាំងនោះឃើញគូរនៅទីសំខាន់ៗដូចជា សាលាបុណ្យ សាលាឆាន់ និងជាពិសេសគឺនៅក្នុងព្រះវិហារ។ ប៉ុន្តែប្រសិនបើគំនូរបង្ហាញអំពីនរក និងប្រេតមានតែមួយផ្ទាំង គេច្រើនគូរនៅទិសខាងលិច ដែលអ្នកស្រាវជ្រាវយល់ថាពាក់ព័ន្ធនឹងជំនឿទិសនៃសេចក្តីស្លាប់ៗ[5] ដោយឡែក ចំពោះហេតុជាផលបាបនាំឱ្យធ្លាក់នរក ឬកើតជាប្រេតដែលខ្មែរជឿ ព្រមទាំងនៅចងចាំលើកមកគូរនោះមានដូចជា បាបជល់មាន់ សម្លាប់សត្វ ស្មូចត្រីក្នុងវត្ត លែងគោក្របីចូលវត្ត បង្ខិតព្រំដី សាហាយស្មន់ បំបែកបំបាក់សង្ឃ ព្រះសង្ឃឆាន់មិនចម្រើនអជ្ជៈ ។ល។ សូមរម្លឹកថា ក្នុងជំនឿខ្មែរ "ប្រេត" ជាអមនុស្សមួយបែប មានជាប់ទាក់ទងតែក្នុងបរិបទវត្តអារាមប៉ុណ្ណោះ។[6]

ប៉ុន្តែយ៉ាងណាក្តីបើតាម "នរកកថា" ហេតុនាំឱ្យធ្លាក់មានដូចជា អ្នកប្រទូសរាយព្រះឫសីមានសីលធម៌ល្អត្រូវធ្លាក់នរកធំ ព្រះរាជាមិនតាំងនៅក្នុងធម៌ឱ្យរាស្ត្រក្តៅក្រហាយដោយអយុត្តិធម៌ ធ្លាក់ក្នុងនរកមានភ្លើងឆេះកាយ ស្រីសម្លាប់កូនក្នុងពោះ ធ្លាក់នរកពេញទៅដោយផ្តៅមានបន្លាដ៏មុត ហើយស្រីដែលគេលោះមកធ្វើភរិយា ហើយមើលងាយស្វាមី ឬឪពុកម្តាយក្មេក ធ្លាក់នរកមានសន្ទូចថ្លក់ទាញអណ្តាតចេញមក អណ្តាតនោះវែងពេញដោយដង្កូវ។ រីឯអ្នកសម្លាប់មាតាបិតា ធ្លាក់នរកទទួលទារុណកម្មចាក់រុកដោយលំពែងតាមរាងកាយ ចាក់ឱ្យខ្វាក់ភ្នែក ឱ្យស៊ីមូត្រគូថ ឱ្យស៊ីដុំដែកក្រហម ឱ្យឆ្កែខាំក្អែកចឹកស៊ី ភ្ជួរដោយផាលដែកក្រហម ផឹកស៊ីលោហិតខ្លួនឯង ផឹកទឹកទង់ដែង ត្រាំក្នុងទឹកមូត្រគូថ ដង្កូវធំមានមាត់ដែកខាំចោះរាងកាយ ធ្លាក់ក្នុងទឹកឈាម និងខ្ទុះដ៏ជ្រៅរាប់រយយោជន៍។

ចំណែកឯបុរស ឬស្ត្រីប្រព្រឹត្តកន្លងភរិយា-ប្តីអ្នកដទៃ ធ្លាក់នរកពេញទៅដោយដើមរកា កម្ពស់១យោជន៍ ត្រូវពួកយមបាលចាក់ឱ្យឡើងដើមរកា ក្នុងវេលាឡើងបន្លារកាឆេះជាអណ្តាតភ្លើងក្ស៊ុងចុះមក ក្នុងវេលាចុះ បន្លានោះបះប្រាងឡើងលើ គ្រារួចចាកនរក

---

[5] សាន ផល្លា ២០០៧: ១៤១

[6] បទបង្ហាញអំពី "ភពអមនុស្សនៅក្នុងជំនឿខ្មែរ" ដោយសាស្ត្រាចារ្យ អាំង ជូលាន រៀបចំដោយអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

នេះហើយ ធ្លាក់ក្នុងនរកពេញដោយទឹកទង់ដែងទៀត។ លើសពីនេះ លោកសម្ដែងថា អ្នកសម្លាប់សត្វ ដល់សត្វមាន់ គោ ក្របី ដល់ត្រី ធ្លាក់នរកដែលពេញដោយទឹកផ្សារ ត្រូវយមបាលចាក់ដោយដែកស្រួច វាយសំពងដោយញញួរ សាប់ដោយដាវព្រឹកល្ងាច ចំណែកអ្នកបង្ខូចគេ ត្រូវនាយយមបាលធ្វើទោសផង ឱ្យស៊ីអាចម៍របស់សត្វនរកដទៃផង ត្រូវសុនខ និងត្មាតចឹកចោះផង (រូបលេខ៦-៨)។[7]



*រូបលេខ៦-៨ ការធ្វើទារុណកម្មសត្វនរក-ប្រេតគូរនៅតាមវត្តផ្សេងៗ*

បើពិនិត្យតាមគំនូរអំពីនរកទាំងឡាយដូចរៀបរាប់ខាងលើ គេសង្កេតឃើញគំនូរ តាមវត្តខ្លះទៀត បង្ហាញឱ្យឃើញទិដ្ឋភាពទារុណកម្មទោសផ្សេងៗប្លែកៗច្រើនសណ្ឋាន ដែលពុំធ្លាប់ឃើញដូចជា ចុករន្ធសត្វមិនឱ្យចេញក្រៅ ធ្វើបុណ្យមានចិត្តមិនស្អាត ដុតព្រៃ ឬលួចល្ពៅ-ត្រឡាចអ្នកដទៃជាដើម។ បាបកម្មទាំងនេះ ប្រហែលមានចែងក្នុងគម្ពីរផ្សេងៗទៀត ដែលអ្នកស្រុកខ្លះធ្លាប់ស្គាល់ ហើយលើកយកមកគូរ។ ដោយឡែក គេឃើញទោសជល់មាន់ គឺជាគំនូរដែលហាក់ដូចជាមនុស្សខ្មែរស្គាល់ទូទៅ និងពេញនិយមគូរស្ទើរគ្រប់វត្ត។ មិនតែប៉ុណ្ណោះ ល្បែងនេះគេឃើញមានតាំងពីសម័យអង្គរ ឆ្លាក់នៅជញ្ជាំងប្រាសាទបាយ័ន្តផង និងអង្គរវត្តផង (រូបលេខ៩-១០)។[8] ចំពោះទារុណកម្មនៃទោសជល់មាន់នេះ គេច្រើនគូរបង្ហាញជារូបជាខ្លួនមនុស្ស មានក្បាលជាសត្វមាន់ មានសៀតពូថៅ ឬកាំបិតនៅចង្កេះ ឬកាន់នៅដៃ ហើយត្រូវពួកយមបាលបង្ខំឱ្យជល់ ឬកាប់ចាក់គ្នាហូរឈាមស្រោចខ្លួន។

[7] ឱម ណាត្រី (ឆ្នាំ?): ៦០-៦៣

[8] សូមអានអត្ថបទ "ប្រជល់ក្នុងចម្លាក់បុរាណខ្មែរ" ដោយ សុខ កែវវណ្ណារ៉ា ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/6341 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





*រូបលេខ៩ ចម្លាក់ជល់មាន់នៅប្រាសាទអង្គរវត្ត, សតវត្សទី១២ (រូបៈ សុខ កែវណ្ណារ៉ា)*

*រូបលេខ១០ ចម្លាក់ជល់មាន់នៅប្រាសាទបាយ័ន្ត, ចុងសតវត្សទី១២ ដើមសតវត្សទី១៣*

*ដូច្នេះជាសង្ខេបមក បើផ្អែកតាមជំនឿដែលបង្ហាញអំពី "នរក" តាមរយៈគំនូរនានានៅតាមវត្ត គេសង្កេតឃើញគូរបង្ហាញនៅតាមទីសំខាន់ៗដូចជា ព្រះវិហារ សាលាឆាន់ ឬសាលាបុណ្យ ក្នុងន័យក្រើនរម្លឹកពុទ្ធសាសនិកកុំឱ្យសាងអកុលកម្មទាំងនោះ។ ទន្ទឹមនឹងនេះ ទោសកំហុសលើកមកបង្ហាញដែលនាំឱ្យធ្លាក់នរក ឬកើតជាប្រេតនោះសោត ពុំមានច្រើនប្រការដូចក្នុងគម្ពីរសម្តែង ឬឆ្លាក់នៅអង្គរវត្ត (នរក៣២) ឡើយ។ ប៉ុន្តែអ្វីដែលខ្មែរនៅជឿថាជាបាបនាំឱ្យធ្លាក់ទៅនរក ភាគច្រើនជាសកម្មភាពអកុសលកម្ម ដែលគេតែងសង្កេតឃើញតាមរយៈសកម្មភាពប្រចាំថ្ងៃ៕*

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

# ឯកសារយោង

គង់ ឈួយ

១៩៦៤, *ព្រះមាល័យទេវសា*, បណ្ណាគារត្រៃរតន៍, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, វៃយំ, ភ្នំពេញ

សុខ កែវវណ្ណារ៉ា

២០២១, "ប្រជល់ក្នុងចម្ងាក់បុរាណខ្មែរ" ផ្សាយលើគេហទំព័រ

https://ams.com.kh/khmercivilization/detail/6341 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

អាំង ជូលាន និង ស៊ីយ៉ុន សុភារិទ្ធ

២០១៩, "ពាក្យសូត្រចាប់បាយបិណ្ឌ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ.៦៨-៧១, យសោធរ, ភ្នំពេញ

អាំង ជូលាន

២០២២, "ភពអមនុស្សនៅក្នុងជំនឿខ្មែរ", *បទបង្ហាញរៀបចំដោយអាជ្ញាធរជាតិអប្សរា*, នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២

ឱម ណាគ្រី

(ឆ្នាំ?), *នរកថា*, បណ្ណាគារត្រៃរតន៍, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត